# អ្នកតា តាលាក់

ប្រជុំរឿងព្រេងខ្មែរភាគ ៨ ពីទំព័រទី ១៨៣ – ១៨៥

---

នៅក្នុងឃុំកៀនជ្រៃ ស្រុកកំពង់សៀម (កំពង់ចាម) ឮគេដំណាលថា កាលដែលស្រុកខ្មែរកើតវិបរិតជាមួយនឹងចាម ទ័ពខ្មែរមានជ័យជម្នះបានដេញទ័ពចាមខ្ចាត់ខ្ចាយអស់ ។ មេទ័ពចាមមួយ បានភៀសខ្លួនចូលទៅក្នុងពួនក្នុងព្រៃអំពៅ ដោយអត់អាហារយូរថ្ងៃពេក ក៏ស្លាប់នៅទីនោះទៅ តែដោយកំហឹងគំនុំគំកួននឹងបច្ចាមិត្តខ្លាំងពេក ក៏កើតជាអ្នកតាមួយពូកែអស្ចារ្យ ។ លុះអ្នកស្រុកដឹងថាមានអ្នកតាពូកែ ក៏ធ្វើរោងក្បឿងមួយខ្ទងគ្របលើផ្នូរអ្នកតា លាក់ ។ តាលាក់ នេះ គាត់ធ្វើតែអ្នកណាដែលស៊ីសាច់ជ្រូក ព្រោះគាត់ចាម ដូច្នេះអ្នកស្រុកកៀនជ្រៃ ប៉ែកខាងជើងព្រែកទាំងមូល មិនហ៊ានយកសាច់ជ្រូកចូលទៅក្នុងស្រុកភូមិទេ បើមានបុណ្យទានអ្វី ប្រើតែសាច់គោនិងប្រេងប៉ុណ្ណោះ ។ ពីឆ្នាំ ១៩៣៦ ឬ ៣៧ មានឈ្មោះ ហ៊ុល ហេន នៅស្រុកស្ទឹងត្រង់ កំពង់ចាម បានទិញឡានមួយយកទៅរត់ឈ្នួលឯស្ទឹងត្រង់ បើកឡានទៅដល់រោងតាលាក់ ក៏ចុះទៅបន់សុំឲ្យជួយ ឲ្យបានចម្រើនក្នុងរបររត់ឡាននេះ និងថ្វាយទេសឯកប្រឹងផ្ទរ ហើយក៏ចេញឡានទៅ ។ យប់នោះឯងតាលាក់ទៅពន្យល់សប្តិ ហ៊ុល ហេន ថា "អញមករក្សាឡានឲ្យហើយ តែកុំទទួលដាក់សាច់ជ្រូកឲ្យសោះ" ។

ពីរបីខែដំបូង ហ៊ុល ហេន មិនហ៊ានទទួលដាក់អ្នកជិះឯណាដែលមានសាច់ជ្រូកសោះ រកស៊ីឃើញចំណេញគ្រាន់ទប់ទល់ តៗមកម្ចាស់ឡានចេះតែលួចដាក់សាច់ជ្រូកបន្តិចៗ ឡានចេះតែខូច បែកកង់ ខូចម៉ាស៊ីន មួយថ្ងៃធ្លាប់រត់បានបីជើង ទៅជាមិនបានមួយជើងផងក៏មាន ខាតៗទៅទាល់តែរកស៊ីលែងបាន ។ ម៉្យាងទៀត តាលាក់នេះពីដើមនៅក្បែរមាត់ទន្លេទេ លុះដីបាក់ជិតៗមក ក៏ស្រាប់តែឃើញផ្នូរគាត់ ទៅនៅឯកណ្តាលចម្ការ ឆ្ងាយពីមាត់ទន្លេទៅវិញ អ្នកស្រុកក៏រើរោងតាមទៅ ។

នៅឃុំកៀនជ្រៃ គួរឲ្យសើចណាស់ ត្រើយព្រែកម្ខាង អ្នកស្រុកបរិភោគសាចជ្រូក ត្រើយម្ខាងបរិភោគមិនបាន ជនឯណាចចេសនឹងបានចុកពោះមិនខាន ។

# ក្បួនហែអ្នកតា

ពីល្ងាចសូត្រមន្ត ព្រឹកឡើងប្រគេនចង្ហាន់ដល់ព្រះសង្ឃ រួចហែបាយ ព្រលឹងទៅសុំពរសព្ទសាធុការពីអ្នកតា សុំឲ្យមានទឹកភ្លៀងបរិបូណ៌ ធ្វើស្រែចម្ការឲ្យបានល្អ សុំកុំឲ្យមានជំងឺដង្កាត់ និងសុំឲ្យស្រុកបានសុខសាន្តត្រាណជាដើម ។ បាយ

ព្រលឹងនេះ គេយកទៅជូនអ្នកណាដែលធំជាងគេក្នុងខេត្រ មានអភិបាលខេត្រ ឬអភិបាលស្រុកជាដើម ។ តាមទំនៀម ដែលឡើងអ្នកតា បើធ្វើតាមទម្លាប់នោះ ត្រូវសង់រោងយ៉ាងអ៊ឹកធឹកណាស់ មានល្បែង របាំ ភ្លេងភ្លាត់ មេឃុំម្នាក់ត្រូវធ្វើ រោងរបស់ខ្លួន ។ ម៉្យាងទៀត គេត្រូវកាប់ក្របីឃ្លៀចថ្វាយអ្នកតាផង ទំនៀមថ្វាយសត្វរស់នេះ មានធ្វើនៅខេត្របាភ្នំ ចំពោះអ្នកតាមេស នៅខេត្រស្ទឹងត្រែង ។ល។ ក្នុងស្រុកកំពង់ត្របែក នៅឃុំព្រះធាតុ មានអ្នកតានាងសល្អស្អាត អ្នកតា នោះស៊ីតែទន្សាយ ។ អ្នកស្រុកនិយាយថា នៅឱកាសដែលរៀបពិធីឡើងអ្នកតា តែមានទន្សាយរត់ចូលមក ឲ្យចាប់ សម្លាប់ថ្វាយអ្នកតាភ្លាម ឥឡូវនេះគេបានយកជ្រូកជំនួសទន្សាយវិញ ។

## តង្វាយអ្នកតា

អ្នកតាទាំងអស់លើកលែងតា លាក់ និងយាយ ទេពចេញសុទ្ធតែត្រូវការក្បាលជ្រូកទាំងអស់ ចំណែកតាលាក់ និង យាយ ទេព ត្រូវការបាយដំណើប ប្រហុកអាំង សំពត់ស ក្លស់ ទៀន ធូប ។ អ្នកតាឯទៀតត្រូវការសំណែនជាបាយម្ហូប ស្រាក៏មាន ចេកស្លាធម៌ក៏មាន ។ល។